www.kidworship.kr

# ចំណោងជើង៖ ព្រះយេស៊ូស្រឡាញ់ដល់ក្មេងៗ


17Page

**Narration** ព្រះយេស៊ូបានមកដល់ភូមិមួយ របស់សាសន៍យូដាជាមួយនិងពួកសិស្ស របស់ទ្រង់
ដើម្បីនឹងអធិប្បាយនូវព្រះបន្ទូលពីព្រះរាជ្យរបស់ព្រះជាម្ចាស់។
គ្រប់ទីកន្លែងដែលព្រះយេស៊ូបានទៅ គឺតែងតែមានហ្វូងមនុស្សប្រមូលផ្តុំគ្នា។
ក្នុងចំណោមពួកគេមានឪពុកម្តាយខ្លះ បាននាំយកកូនតូច របស់ពួកគេមកជាមួយដែរ។

**ឪពុកម្តាយទី១** “ទីបំផុត! ព្រះយេស៊ូបានមកដល់ភូមិរបស់ពួកយើងហើយ”។

**ឪពុកម្តាយទី២** “តោះកូន! យើងនាំគ្នាទៅជួបព្រះយេស៊ូ ស្តាប់ពីអ្វីដែលព្រះអង្គទ្រង់មានព្រះបន្ទូល”។

**Narration** ក្មេងៗពួកគេពិតជាមានភាពសប្បាយរីករាយណាស់
នៅពេលដែលពួកគេបានជួបជាមួយព្រះយេស៊ូ!


18Page

**Narration** ទ្រង់នៅទីនោះ! ព្រះយេស៊ូនៅទីនោះ! ក្មេងៗបានលោតឡើង
ហើយនាំគ្នារត់តំរង់ទៅឯព្រះយេស៊ូ
ប៉ុន្តែនៅពេលដែលក្មេងៗបានព្យាយាមទៅជិតព្រះយេស៊ូ
ពួកសិស្សរបស់ព្រះអង្គបានរារាំង ក្មេងៗនិង ឪពុកម្តាយរបស់ពួកគេ។

**សិស្សទី១** ព្រះយេស៊ូកំពុងបង្រៀនព្រះបន្ទូល នៅពេលនេះអ្នកមិនអាចនាំក្មេងៗចូលបានទេ!
ទេ!ទេ! មិនអាចចូលបានទេ!

**សិស្សទី២** “ក្មេងៗនឹងធ្វើឲ្យមានឮសំឡេងខ្លាំង ហើយឆាឆៅ រញ៉េរញ៉ៃ។
ព្រះយស៊ូទ្រង់មិនចូលចិត្តទេ! សូមចេញទៅ។

**ក្មេង** ប៉ុន្តែខ្ញុំចង់ឃើញព្រះយេស៊ូ.....(ក្មេងៗយំ)


19Page

**Narration** ព្រះយេស៊ូបានឃើញពីអ្វីដែលអ្នកទាំងនោះកំពុងតែធ្វើ
ដូច្នេះទ្រង់បានបន្ទោសទៅកាន់សិស្សរបស់ទ្រង់។

**ព្រះយេស៊ូ** ចូរឲ្យក្មេងៗទាំងនេះចូលមកឯខ្ញុំចុះ! កុំរារាំងពួកគេឡើយ
ដ្បិតមានតែអ្នកមានចិត្តដូចក្មេងៗទាំងនេះប៉ុណ្ណោះ
ដែលអាចចូលទៅកាន់ព្រះរាជ្យនៃស្ថានបរមសុខបាន! សិស្សជាទីស្រឡាញ់អើយ
នេះជាការពិត បើអ្នកមិនធ្វើដូច្នោះអ្នកក៏មិនអាចចូលទៅស្ថានបរមសុខបានដែរ។


20Page

**Narration** ព្រះយេស៊ូទ្រង់បានរាក់ទាក់ដល់ក្មេងៗ ទ្រង់បានឱបពួកគេដោយព្រះហស្តរបស់ទ្រង់
ហើយផ្តល់ព្រះពរទៅកាន់ពួកគេតាមរយៈព្រះហស្តនៃទ្រង់។

**ក្មេងទី១** “វ៉ាវ.…ព្រះយេស៊ូ ពុកចង្ការរបស់ទ្រង់ពិតជាស្អាតណាស់” ។

**ក្មេងទី២** “ព្រះយេស៊ូ! សូមទ្រង់និយាយរឿងទៀតមក”

**ព្រះយេស៊ូ** “បាន! បាន! ហាសហាសហ៉ា!”

**Narration** គ្រប់ទីកន្លែងដែលទ្រង់បានយាងទៅ ព្រះយេស៊ូតែងតែរាក់ទាក់ទៅកាន់ក្មេងៗ
ទ្រង់មិនដែលគិតថាពួកគេជាមនុស្សរញ៉េរញ៉ៃឆាឆៅឡើយ
ទ្រង់តែងតែផ្តល់ក្តីស្រឡាញ់សំរាប់ពួកគេ។